ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...០៦...សរ....

# សារាចរ
## ស្តីពី
## ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលតែងតែប្រារព្ធទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ នៅថ្ងៃទី០១ ខែតុលា ក្នុងគោលបំណងជំរុញការលើកកម្ពស់កិច្ចគាំពារ និងការលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់នៅទូទាំងប្រទេស ក៏ដូចជាដើម្បីបង្ហាញឱ្យឃើញអំពីតួនាទីដ៏សំខាន់របស់មនុស្សចាស់ និងបុព្វការីជនដែលបានបង្កើតធនធានដ៏មានសារៈប្រយោជន៍ ព្រមទាំងបានផ្តល់នូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍យ៉ាងសម្បូរបែប សម្រាប់មនុស្សជំនាន់ក្រោយ ដែលប្រធានបទសម្រាប់ឆ្នាំនេះ គឺ «សមាគមមនុស្សចាស់បង្កើនសាមគ្គី **ដើម្បីអភិវឌ្ឍសហគមន៍និងសង្គមជាតិ**»។ ការប្រារព្ធទិវានេះ គឺជាការរម្លឹកដល់គុណូបការៈរបស់មនុស្សចាស់កម្ពុជា បុព្វការីជន ជីដូន ជីតា ឪពុកម្តាយ អ៊ុំ ពូ មីង ដែលបានកសាងនិងបន្សល់ទុកនូវកេរមរតកដ៏ថ្លៃថ្លាសម្រាប់កូនចៅជំនាន់នេះ និងជំនាន់ក្រោយៗទៀត។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ខ្ពស់ចំពោះមនុស្សចាស់នៅទូទាំងប្រទេស តាមរយៈការបង្កើតឱ្យមានគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ដើម្បីទទួលបន្ទុករៀបចំគោលនយោបាយជាតិ សំដៅធ្វើយ៉ាងណាលើកស្ទួយដល់សុខុមាលភាពនិងជីវភាពរស់នៅរបស់មនុស្សចាស់។

ដើម្បីរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិនាឆ្នាំនេះ ឱ្យប្រព្រឹត្តទៅបានទូលំទូលាយ ក៏ដូចជាដើម្បីផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋគ្រប់វ័យ បានយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃទិវានេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅៈ

១-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ត្រូវសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីចាត់តាំងមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥នេះ ឱ្យបានអធិកអធម។

២-រាជធានី ខេត្តត្រូវរៀបចំមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ដោយបង្កលក្ខណៈឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃ បព្វជិត លោកយាយ លោកតា ព្រមទាំងប្រជាពលរដ្ឋគ្រប់វ័យ បានចូលរួមកាន់តែច្រើនឡើងថែមទៀត ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែទូលំទូលាយអំពីសារៈសំខាន់នៃគោលនយោបាយជាតិចំពោះមនុស្សចាស់កម្ពុជា។

៣-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ សូមបន្តជួយគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍សមាគមមនុស្សចាស់ដែលមានស្រាប់ និងបង្កើតបន្ថែមទៀតនៅតាមសហគមន៍មូលដ្ឋាននៅគ្រប់ឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កើនការយកចិត្តទុកដាក់អនុវត្តតាមការណែនាំនិងបង្កើតឱ្យមានសមាគមមនុស្សចាស់ក្នុងមូលដ្ឋានគ្រប់ឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើនស្មារតីសាមគ្គីភាព និងការជួយគ្នាទៅវិញទៅមក ជាពិសេសត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការជួយដល់ជនចាស់ជរា ជនពិការ ជនក្រីក្រ និងទុគ៌តជន នៅតាមមូលដ្ឋានរបស់ខ្លួន។

៤- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកម្មវិធីចុះសំណេះសំណាលជាមួយមនុស្សចាស់នៅតាមមូលដ្ឋាន វត្តអារាម និងវិហារសាសនានានា ដោយនាំយកជំនួយឧបត្ថម្ភតាមសទ្ធាជ្រះថ្លា ជួយដល់ជនចាស់ជរា ជនពិការ ជនក្រីក្រ និងទុរគតជន។

៥- ក្រសួងធម្មការនិងសាសនាត្រូវធ្វើការណែនាំនិងជំរុញចលនានៅតាមវត្តអារាម វិហារសាសនាទូទាំងប្រទេស តាមរយៈបព្វជិតសាសនា ដើម្បីឱ្យមានសកម្មភាពជួយឧបត្ថម្ភគាំទ្រដល់ជនចាស់ជរា ជនពិការ ជនក្រីក្រ និងទុរគតជន។

៦- ក្រសួងព័ត៌មានត្រូវណែនាំបណ្តាញព័ត៌មានរដ្ឋនិងឯកជនទាំងអស់ ឱ្យធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីខ្លឹមសារនិងសកម្មភាពនៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥។

៧- គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំបដានៅតាមអង្គភាព និងទីសាធារណៈ តាមខ្លឹមសារដូចតទៅ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា!
- អបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ០១ តុលា
- មនុស្សចាស់ជាមរតកដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារនិងសង្គមជាតិ
- ការគោរពដឹងគុណចំពោះមនុស្សចាស់គឺជាកតញ្ញុតាធម៌ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន
- កសាងសង្គមដែលមានការអភិវឌ្ឍសម្រាប់មនុស្សគ្រប់វ័យ
- សមាគមមនុស្សចាស់ជាយន្តការដ៏សំខាន់ ជួយអភិវឌ្ឍសហគមន៍និង សង្គមជាតិ។

៨- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវធ្វើការណែនាំអនុវត្តតាមសារាចរនេះ និងបូកសរុបលទ្ធផលការងារជូនរាជរដ្ឋាភិបាល។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ